ខោនធី LOS ANGELES
មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

# ព្រមាន៖ ការទាក់ទាញរកសម្លេងឆ្នោត ត្រូវបានហាមឃាត់!

## ការបំពានអាចនាំទៅដល់ការផាកពិន័យ និង/ឬដាក់ពន្ធនាគារ

## នៅទីណា៖

- នៅក្នុងតំបន់ជុំវិញជិតៗរបស់មនុស្សដែលកំពុងតម្រង់ជួរដើម្បីបោះឆ្នោតរបស់ពួកគេ ឬក្នុងចម្ងាយ 100 ហ្វីតពីច្រកចូលនៃកន្លែងបោះឆ្នោត ការបោះឆ្នោតនៅជាប់ផ្លូវ ឬប្រអប់ទម្លាក់ឆ្នោត សកម្មភាពខាងក្រោមត្រូវបានហាមឃាត់ ។

## តើសកម្មភាពអ្វីខ្លះដែលត្រូវបានហាមឃាត់៖

- សូមកុំ សុំឱ្យបុគ្គលណាម្នាក់បោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការសន្លឹកឆ្នោតណាមួយ។
- សូមកុំ បង្ហាញឈ្មោះ រូបភាព ឬនិមិត្តសញ្ញារបស់បេក្ខជន។
- សូមកុំ រារាំងការចូលទៅកាន់ ឬក៏ពន្យាពេល នៅក្បែរប្រអប់ទម្លាក់សន្លឹកឆ្នោតណាមួយ។
- សូមកុំ ផ្តល់សម្ភារៈ ឬព័ត៌មានដែលអាចស្តាប់បានសម្រាប់ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការសន្លឹកឆ្នោតណាមួយនៅជិតកន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬប្រអប់ទម្លាក់សន្លឹកឆ្នោត។
- សូមកុំ ផ្សព្វផ្សាយញត្តិទាមទារណាមួយ រួមទាំងសម្រាប់ការផ្តួចផ្តើមគំនិត ការធ្វើប្រជាមតិ ការបោះឆ្នោតដកតំណែង ឬការតែងតាំងបេក្ខជន។
- សូមកុំ ចែកចាយ បង្ហាញ ឬស្លៀកសម្លៀកបំពាក់ណាមួយ (មួក អាវ សញ្ញា ប៊ូតុង ស្ទីគ័រ) ដែលរួមបញ្ចូលឈ្មោះ រូប និមិត្តសញ្ញា និង/ឬគាំទ្រ ឬប្រឆាំងបេក្ខជន ឬវិធានការសន្លឹកឆ្នោតណាមួយ។
- សូមកុំ បង្ហាញព័ត៌មាន ឬនិយាយទៅកាន់អ្នកបោះឆ្នោតអំពីសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោត។
- ការហាមឃាត់ការទាក់ទាញរកសម្លេងឆ្នោតដែលបានសង្ខេបខាងលើមានចែងក្នុងមាត្រា 7 នៃជំពូកទី 4 នៃផ្នែកទី 18 នៃក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា។

# ព្រមាន៖ ការកែប្រែបំផ្លែងដំណើរការ ការបោះឆ្នោតត្រូវបានហាមឃាត់!

## ការបំពានទាំងឡាយនឹងត្រូវពិន័យ និង/ឬដាក់ពន្ធនាគារ

### តើសកម្មភាពអ្វីខ្លះដែលត្រូវបានហាមឃាត់៖

- សូមកុំ ប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តការក្លែងបន្លំការបោះឆ្នោត។
- សូមកុំ ផ្តល់សំណង ឬការសូកប៉ាន់ដល់បុគ្គលណាក៏ដោយ ក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយ ដែលជំរុញ ឬ ព្យាយាមជំរុញមនុស្សឱ្យបោះឆ្នោត ឬបដិសេធមិនទៅបោះឆ្នោត។
- សូមកុំ បោះឆ្នោតដោយខុសច្បាប់។
- សូមកុំ ព្យាយាមបោះឆ្នោត ឬជួយអ្នកដទៃឱ្យបោះឆ្នោត នៅពេលដែលមិនមានសិទ្ធិបោះឆ្នោត។
- សូមកុំ ចូលរួមក្នុងការទាក់ទាញរកសន្លឹកឆ្នោត ថតរូប ឬធ្វើកំណត់ត្រាអ្នកបោះឆ្នោតដែលចូល ឬចេញពីកន្លែងបោះឆ្នោត ឬ រារាំងផ្លូវចូល ច្រកចេញ ឬចំណតរថយន្ត។
- សូមកុំ ជំទាស់សិទ្ធិបោះឆ្នោតរបស់បុគ្គលម្នាក់ ឬរារាំងអ្នកបោះឆ្នោតមិនឱ្យបោះឆ្នោត។ ពន្យារពេលដំណើរការបោះឆ្នោត; ឬ ក្លែងបន្លំណែនាំជនណាម្នាក់ថាគាត់មិនមានសិទ្ធិបោះឆ្នោត ឬមិនបានចុះឈ្មោះបោះឆ្នោត។
- សូមកុំ ព្យាយាមបញ្ជាក់ពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោតលើសន្លឹកឆ្នោតរបស់ពួកគេ។
- សូមកុំ កាន់កាប់ ឬរៀបចំឱ្យមាននរណាម្នាក់កាន់កាប់អាវុធ នៅជិតកន្លែងបោះឆ្នោត លើកលែងតែករណីមួយចំនួន។
- សូមកុំ បង្ហាញខ្លួន ឬរៀបចំឱ្យនរណាម្នាក់បង្ហាញខ្លួនក្នុងឯកសណ្ឋានមន្ត្រីសន្តិភាព អ្នកយាម បុគ្គលិកសន្តិសុខ នៅក្នុងតំបន់ជុំវិញជិតកន្លែងបោះឆ្នោត លើកលែងតែករណីលើកលែងមួយចំនួន។
- សូមកុំ ជ្រៀតជ្រែក ឬរំខានជាមួយផ្នែកណាមួយនៃប្រព័ន្ធបោះឆ្នោត។
- សូមកុំក្លែងបន្លំ ក្លែងក្លាយ ឬរំខានដល់សន្លឹកឆ្នោត។
- សូមកុំកែឆ្នៃបំផ្លែងសន្លឹកឆ្នោត។
- សូមកុំរំខាន បំផ្លាញ ឬផ្លាស់ប្តូរបញ្ជីបោះឆ្នោត សន្លឹកឆ្នោតផ្លូវការ ឬធុងសន្លឹកឆ្នោត។
- សូមកុំបង្ហាញធុងប្រមូលសន្លឹកឆ្នោតក្រៅផ្លូវការណាមួយដែលអាចបញ្ឆោតអ្នកបោះឆ្នោតឱ្យជឿថាវាជាប្រអប់ប្រមូលសន្លឹកឆ្នោតផ្លូវការ។
- សូមកុំ រំខាន ឬជ្រៀតជ្រែកជាមួយច្បាប់ចម្លងលទ្ធផលនៃការបោះឆ្នោត។
- សូមកុំ បង្ខិតបង្ខំ ឬបញ្ឆោតបុគ្គលដែលមិនអាចអាន ឬចាស់ជរាឱ្យបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការដែលផ្ទុយនឹងចេតនារបស់ពួកគេ។
- សូមកុំ ធ្វើខ្លួនដូចជាមន្ត្រីរៀបចំការបោះឆ្នោត នៅពេលដែលអ្នកមិនមែនជាបុគ្គលនោះទេ។
- និយោជកមិនអាចទាមទារ ឬសុំឲ្យនិយោជិតរបស់ពួកគេនាំយកសន្លឹកឆ្នោតបោះតាមសំបុត្រទៅធ្វើការ ឬសុំឲ្យនិយោជិតរបស់ពួកគេបោះឆ្នោតសន្លឹកឆ្នោតរបស់ពួកគេនៅកន្លែងធ្វើការនោះទេ។ នៅពេលបើកប្រាក់ខែ ឬប្រាក់ឈ្នួល និយោជកមិនអាចភ្ជាប់នូវសម្ភារៈដែលប៉ុនប៉ងមានឥទ្ធិពលលើគំនិតនយោបាយ ឬសកម្មភាពរបស់និយោជិតរបស់ពួកគេឡើយ។
- សមាជិកក្រុមការងារមណ្ឌលបោះឆ្នោតមិនអាចព្យាយាមកំណត់ពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោតរបស់ពួកគេទេ ឬប្រសិនបើព័តមាននោះត្រូវបានរកឃើញ សូមបញ្ជាក់ពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោតលើសន្លឹកឆ្នតរបស់ពួកគេ។
- ការហាមឃាត់លើសកម្មភាពទាក់ទងនឹងអំពើបំផ្លែងដំណើរការបោះឆ្នោតដែលបានសង្ខេបមកខាងលើមានចែងក្នុងជំពូកទី 6 នៃផ្នែកទី 18 នៃក្រមបោះឆ្នោតរដ្ឋកាលីហ្វ័ញ៉ា។